ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៧៦ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការបង្កើតគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១០០៧ អនក្រ.តត ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣ ស្តីពីការផ្ទេរគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

សម្រេច

មាត្រា ១.-

ត្រូវបានបង្កើត "គណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់" ដែលហៅកាត់ថា "គ.ប.ច." ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រសួងយុត្តិធម៌។

គ.ប.ច. មានសមាសភាពដូចខាងក្រោម ៖

១-	ឯកឧត្តម អង្គ វង្សវឌ្ឍនា	ប្រធាន
២-	ឯកឧត្តម ហ៊ី សោភា	អនុប្រធានប្រចាំការ
៣-	ឯកឧត្តម ច័ន្ទ សំណព្វ	អនុប្រធាន
៤-	ឯកឧត្តម កើត រិទ្ធ	អនុប្រធាន

www.pheakdeylaw.com

៥- ឯកឧត្តម កាន ច័ន្ទមេត្តា សមាជិក
៦- ឯកឧត្តម យក់ ប៊ុនណា សមាជិក
៧- ឯកឧត្តម ប៊ុន ហុន សមាជិក
៨- ឯកឧត្តម យាង សេង សមាជិក
៩- ឯកឧត្តម សូ មុយយៀង សមាជិក
១០-ឯកឧត្តម ថេង ច័ន្ទសង្វារ សមាជិក
១១-ឯកឧត្តម ស៊ា ម៉ៅ សមាជិក
១២-ឯកឧត្តម ប៉ែន ពេជ្រសាលី សមាជិក
១៣-ឯកឧត្តម តាន់ហ៊ាង ដាវ៉ែណ្ណ សមាជិក
១៤-ឯកឧត្តម ផូវ សំភី សមាជិក
១៥-ឯកឧត្តម ហ៊ែល ចំរើន សមាជិក
១៦-ឯកឧត្តម ស៊ូ សុជាតិ សមាជិក
១៧-ឯកឧត្តម ហ៊ឹង គីមថន សមាជិក
១៨-លោក សឹង ផុស សមាជិក
១៩-លោកស្រី ចាំង ស៊ីណាត សមាជិក
២០-កញ្ញា ហេ ផល្លាសម្បត្តិ សមាជិក
២១-លោក អែម ឧត្តម សមាជិក
២២-លោក ហ៊ិន ឈុនតេង សមាជិក។

គ.ប.ច. អាចមានសមាសភាពបន្ថែមផ្សេងទៀត ដែលត្រូវជ្រើសរើសចេញពីក្នុងចំណោមឥស្សរជន ឬមន្ត្រីរាជការ ដែលមានចំណេះដឹង និងបទពិសោធន៍ការងារក្នុងវិស័យនីតិសាស្ត្រ រដ្ឋបាល សេដ្ឋកិច្ច ហិរញ្ញវត្ថុ ឬអក្សរសាស្ត្រ និងត្រូវតែងតាំងដោយអនុក្រឹត្យដោយឡែក តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវចាត់បញ្ជូនតំណាង ទៅតាមសេចក្តីស្នើសុំរបស់គ.ប.ច.។

មាត្រា ២..

គ.ប.ច. អាចមានទីប្រឹក្សាជាតិ និងអន្តរជាតិមួយចំនួនតាមការចាំបាច់ ដែលពុំមែនជាសមាជិករបស់គណៈកម្មការនេះទេ។ ទីប្រឹក្សា ត្រូវបានអញ្ជើញឱ្យចូលរួមជាមួយគ.ប.ច. គ្រប់ពេល។ ទីប្រឹក្សាអាចជូនមតិយោបល់បាន ប៉ុន្តែពុំមានសិទ្ធិចូលរួមបោះឆ្នោតសំដែងមតិនៅក្នុងគណៈកម្មការឡើយ។

មាត្រា ៣..

គ.ប.ច. មានភារកិច្ចពិនិត្យ និងអនុម័តពាក្យច្បាប់ដែលកំពុងប្រើប្រាស់ ពាក្យច្បាប់ថ្មី និងពាក្យច្បាប់ដែលបកប្រែពីភាសាបរទេស។ នីតិវិធីនៃការពិនិត្យ និងអនុម័តពាក្យច្បាប់របស់គ.ប.ច. ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងមួយ ដែលអនុម័តដោយគណៈកម្មការនេះ។

www.pheakdeylaw.com

ពាក្យច្បាប់ទាំងឡាយដែលគ.ប.ច.អនុម័តរួចហើយ ត្រូវចងក្រងជាសទ្ទានុក្រម និងត្រូវបញ្ជូនទៅប្រមុខរាជរដ្ឋាភិបាល ដើម្បីសុំការប្រកាសឱ្យប្រើនៅទូទាំងប្រទេស។

គ.ប.ច. មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងយុត្តិធម៌ ដើម្បីដំណើរការការងាររបស់ខ្លួន។

មាត្រា ៤.-

គ.ប.ច. មានលេខាធិការដ្ឋានមួយជាសេនាធិការ និងជាអង្គភាពបច្ចេកទេស ដែលជួយគណៈកម្មការក្នុងការងារព្រាងពាក្យច្បាប់ ការងាររដ្ឋបាល ការងារគណនេយ្យ និងហិរញ្ញកិច្ច ព្រមទាំងការងារផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងគណៈកម្មការ។

លេខាធិការដ្ឋាននៃគ.ប.ច. មានភារកិច្ចដូចតទៅ ៖

- ព្រាងបញ្ជីពាក្យច្បាប់ និងបកប្រែពាក្យច្បាប់បរទេសមកពាក្យច្បាប់ខ្មែរ ដើម្បីពិនិត្យ និងសម្រេច ដោយរៀបចំជាសទ្ទានុក្រមពាក្យច្បាប់·
- បោះពុម្ពឯកសារសម្រាប់ដំណើរការការងាររបស់គ.ប.ច.ទាំងមូល
- រៀបចំការប្រជុំរបស់គ.ប.ច.
- ធ្វើកំណត់ហេតុ និងរបាយការណ៍នៃអង្គប្រជុំ
- រៀបចំចងក្រង និងបោះពុម្ពពាក្យច្បាប់ដែលអង្គប្រជុំបានអនុម័ត
- រៀបចំបោះពុម្ពសទ្ទានុក្រមពាក្យច្បាប់ និងរដ្ឋបាល
- រៀបចំ និងចែកផ្សាយសទ្ទានុក្រមពាក្យច្បាប់ និងរដ្ឋបាល
- អនុវត្តការងារផ្សេងៗទៀតដែលគ.ប.ច.ប្រគល់ឱ្យ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគ.ប.ច. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

លេខាធិការដ្ឋាននៃគ.ប.ច. ដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួនតាមការចាំបាច់។ សមាសភាពនៃលេខាធិការដ្ឋាននេះ ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

មាត្រា ៥.-

គ.ប.ច. មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិ ដែលជាកញ្ចប់ថវិកាដោយឡែក នៅក្នុងក្របខណ្ឌថវិការបស់ក្រសួងយុត្តិធម៌។

គ.ប.ច. មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិ ដែលបានមកពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការអន្តរជាតិ និងពីប្រភពផ្សេងទៀត សម្រាប់បំពេញការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព។

មាត្រា ៦.-

រាល់កិច្ចប្រជុំរបស់គ.ប.ច. ត្រូវទទួលបានប្រាក់បំណាច់ម៉ោងប្រជុំ។ កម្រៃប្រាក់បំណាច់ម៉ោងប្រជុំ ត្រូវកំណត់ដោយប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

www.pheakdeylaw.com

មាត្រា ៧.-

អនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០៣ ស្តីពីការបង្កើតគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ហើយត្រូវជំនួសដោយអនុក្រឹត្យនេះ។

មាត្រា ៨.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

អង្គ វង្សវឌ្ឍានា

<u>កន្លែងទទួល៖</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com